**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣៣៣✱៤៤

**តុលាការកំពូល**
សំណុំរឿងរដ្ឋប្បវេណី
លេខៈ ៨៤
ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៦
សាលដីកា
លេខៈ ៣៨៤
ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៦

**នាមនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៦
ដោយមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម | **ឌិត មុន្ទី** | ជាប្រធាន |
| ២-លោក | រៀល មួន | ជាចៅក្រម-របាយការណ៍ |
| ៣-លោក | ស៊ិន ឌីម | ជាចៅក្រម |
| ៤-លោក | ឈឹម ស៊ីផល | ជាចៅក្រម |
| ៥-លោក | គង់ ភីរុន | ជាចៅក្រម |
| ៦-លោក | ប៉ែន សាវឿន | ជាចៅក្រម |
| ៧-លោក | យស់ សូខឿន | ជាចៅក្រម |
| ៨-លោក | ម៉ុង មុន្នីចរិយា | ជាចៅក្រម |
| ៩-លោក | យូរ ឧត្តរា | ជាចៅក្រម |

ក្រឡាបញ្ជី
លោកស្រី **អ៊ិង ឡាវី**

តំណាងមហាអយ្យការ
ឯកឧត្តម **ជួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ០៧"ង" ចុះថ្ងៃទី១១ខែមករា ឆ្នាំ២០០៦ នៃស័ណ្ឋរឿងរដ្ឋប្បវេណីលេខ ៤០ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **ទៅ សុវណ្ណា** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុក សៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះជា ប៊ុនរ៉េត "ស"ម្តាយឈ្មោះតៅ អេដែន "ស" ប្រពន្ធឈ្មោះហ៊ាន សុខា ។

មានមេធាវីលោក ឈុន វិនីតា ។

ចុងចម្លើយឈ្មោះ **ជា ចិចឆីន** (ជាចុងបណ្តឹងសាទុក្ខ)ភេទស្រី អាយុ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន ទីលំនៅសព្វថ្ងៃភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុក សៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះជា ឈិន "ស"ម្តាយឈ្មោះខុង ពៃ "ស"ប្តីឈ្មោះឈិត សេងគ្រុយ"ស"កូន០១នាក់។

មានមេធាវីលោក ផាត់ ពៅសាង ។

<u>កម្មវត្ថុបណ្ដឹង</u> : ប្ដឹងសុំសិទ្ធិគ្រប់គ្រងចំណែកដីមរតក

បានឃើញបណ្ដឹងសាទុក្ខលេខ ១៩ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់ឈ្មោះតៅ សុវត្ថា ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ០៧"ង"ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចក្ដីសំរេចទាំងមូល ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៣០ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ របស់លោកមេធាវី ផាត់ ពៅសៀង ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ០៧"ង"ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចមិនដាក់គុកបង្ខំរូបរាងកាយ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៨៤ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៦ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១២-៨-២០០៣ របស់ដើមចោទឈ្មោះតៅ សុវត្ថា ហៅ ជា សុវត្ថា បានប្ដឹងសុំសិទ្ធិគ្រប់គ្រងចំណែកដីមរតករបស់សពឈ្មោះខុង ពៃ ទំហំ ៨.៤ម x ៥៥ម ដោយសំអាងហេតុថា ជីដូនរបស់ខ្លួនឈ្មោះខុង ពៃ បានទទួលមរណភាពកាលពីឆ្នាំ២០០០ ហើយបានបន្សល់ទុកដីមរតក០១ប្លង់ ដែលបានកាន់កាប់តាំងពីក្រោយឆ្នាំ១៩៧៩ ហើយដីនេះជីដូនរបស់ខ្លួនជាអ្នកទិញក្នុងតម្លៃ៣ជីមាស ។ កាលពីជីដូនខ្លួននៅរស់ គាត់បានប្រាប់ឱ្យខ្លួននិង ម្ដាយមីងខ្លួនខ្លួន ឈ្មោះជា គឹមលីន ចែកគ្នារកស៊ីនៅលើដីនេះចុះ ។ ប៉ុន្តែក្រោយពីជីដូនខ្លួនទទួលមរណភាពទៅដល់ពេលនេះឈ្មោះជា គឹមលីន ត្រូវជាម្ដាយមីងខ្លួនបានអះអាងថា ដីនេះជាកម្មសិទ្ធិរបស់គាត់តែម្នាក់ឯងមិនព្រមបែងចែកឱ្យខ្លួន ។

តាមពាក្យបណ្ដឹងសារត្រឡប់ចុះថ្ងៃទី០៤-៩-២០០៣ ឈ្មោះជា គឹមលីន ជាចុងចម្លើយបានប្ដឹងតបថា ខ្លួនប្ដឹងសុំសិទ្ធិគ្រប់គ្រងដីមួយប្លង់ទំហំ ៩អារ៥២សង់ទីអារ ស្ថិតនៅភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប សុំឱ្យឈ្មោះតៅ សុវត្ថា រុះរើតូបចេញពីដីនិងសុំឱ្យរុះរើតង់ចេញពីផ្ទះរបស់ខ្លួន និងប្ដឹងទាមទារសំណងជំងឺចិត្តចំនួន ១០.០០០ដុល្លាអាមេរិក ដោយសំអាងហេតុថា ឈ្មោះតៅ សុវត្ថា ត្រូវជាក្មួយរបស់ខ្លួន ហើយបានស្នាក់នៅលើផ្ទះរបស់ខ្លួនហើយថែមទាំងសាងសង់តូបលក់ដូរនៅពីមុខផ្ទះរបស់ខ្លួន ហើយមានគំនិតទាមទារយកដីដែលជាកម្មសិទ្ធិផ្ទាល់របស់ខ្លួនដោយបានប្រឌិតពាក្យមិនពិតថា ជាដីមរតករបស់សពខុង ពៃ ត្រូវជាម្ដាយរបស់ខ្លួននិងជាជីដូនរបស់គេ រួចប្ដឹងសុំបែងចែកដីនេះជាពីរចំណែក ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២៩០ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការខេត្តសៀមរាប-ឧត្ដរមានជ័យ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះតៅសុវត្ថា ចុះថ្ងៃទី១២-០៨-២០០៣ ទុកជាត្រឹមត្រូវតាមទំរង់ ប៉ុន្តែបដិសេធចោលដោយផ្អែកលើអង្គហេតុនិងគតិច្បាប់ ។

២-ទទួលស្គាល់ពាក្យបណ្ដឹងសារត្រឡប់របស់ចុងចម្លើយឈ្មោះជា គឹមលីន ចុះថ្ងៃទី០៤-៩-២០០៣ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

៣-ទទួលស្គាល់ផ្ទះ និងដីមួយប្លង់ទំហំ៩អារ ៥២សង់ទីអារ ដែលមានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះលី ហេង ,ឈ្មោះចាប សល់, ប្លែក ផារី ខាងត្បូងទល់នឹងផ្លូវជាតិលេខ៦ ឈ្មោះលឹម គីរិន ,ឈ្មោះយ៉ែម ហៀង ខាងកើតទល់នឹងដីឈ្មោះលឹម គីរិន និងច្រកផ្លូវ និងព្រំប្រទល់ផ្នែកខាងលិចទល់នឹងដីឈ្មោះលឹមស៊ិនឡាយ ,ឈ្មោះប្លែក ផារី ,ឈ្មោះឃុង ឃួអី ស្ថិតនៅភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ឈ្មោះជា គិម លីន "ចុងចម្លើយ" មានសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិ ។

៤-សំរេចឱ្យឈ្មោះតៅ សុវត្ថា រុះរើតូបចេញពីលើដី និងរុះរើតវ៉ាន់ចេញពីលើផ្ទះរបស់ឈ្មោះជា គិមលីន ចាប់ពីពេលដែលសាលក្រមចូលជាស្ថាពរ មានអានុភាពយកទៅអនុវត្ត ។

៥-បង្គាប់ឱ្យដើមចោទឈ្មោះតៅ សុវត្ថា សងសំណងជំងឺចិត្តចំនួន ៥០០$(ប្រាំរយដុល្លាអាមេរិក) ទៅចុងចម្លើយឈ្មោះជា គិមលីន ។ សុំលើសពីនេះលើកចោល ។

ក្នុងករណីគ្មានប្រាក់សងទេ ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង បើរឹងរូសត្រូវដាក់គុកបង្ខំលើរូបកាយ ។

៦-សំរេចរឹបអូសប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹង ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីការកោះ ៥.០០០៛ បូករួម៧.០០០៛ ។ ប្រាក់នេះបានកាត់យកពីប្រាក់៧.០០០៛ ដែលដើមចោទបានបង់ទុករួចហើយ ។ កាលបើប្តឹងឧទ្ធរណ៍ ត្រូវបង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រលើតម្លៃដីនិងជំងឺចិត្តដែលតុលាការបានសំរេច ។ ប្រាក់នេះត្រូវដាក់ចូលថវិការដ្ឋ៨០% និងរង្វាន់ក្រឡាបញ្ជី២០% ។ ពន្ធសមាមាត្រនេះ ត្រូវឱ្យចុងចម្លើយបង់មុនទើបបង្គាប់ឱ្យដើមចោទសងទៅចុងចម្លើយវិញជាក្រោយ ។

៧-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍កំណត់ពីរខែ គិតពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ឈ្មោះតៅ សុវត្ថា ហៅជា សុវត្ថា ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ២៩០ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការខេត្ត សៀមរាប-ឧត្តរមានជ័យ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ឈ្មោះជា គិមលីន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ២៩០ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ត្រង់ចំណុចទី៥ អំពីសំណងជំងឺចិត្ត ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៥១"ឈ"ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១១-០២-២០០៤ របស់ឈ្មោះតៅ សុវត្ថា ហៅជា សុវត្ថា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១២-០២-២០០៤ របស់ឈ្មោះជា គិមលីន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ២៩០ ចុះថ្ងៃទី២៣-១២-២០០៣ របស់តុលាការខេត្តសៀមរាប-ឧត្ដរមានជ័យ ទុកជាបានការដដែល ។

៤-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ គឺពន្ធហ្វ៊ីង និងពន្ធចុះបញ្ជីក្ដី ២៥៩០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛. ចំណាយលើការប្រគល់ដីកាកោះ និងអាជ្ញាធរតុលាការ ១០.០០០៛ សរុប ១៣.០០០៛ ។

៥-សាលដីកានេះ ជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៧-០៤-២០០៤ ចំពោះមុខចុងចំលើយ កំបាំងមុខដើមចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦-០៥-២០០៤ ចំពោះមុខមេធាវីតំណាងចុងចំលើយ កំបាំងមុខដើមចោទ ។ បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះតៅ សុវណ្ណា ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥១"ឈ"ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១០៥"ឈ"ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងទាស់ចុះថ្ងៃទី២៤-៥-២០០៤ របស់ឈ្មោះតៅ សុវណ្ណា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ៥១"ឈ"ចុះថ្ងៃទី០៦-០៥-២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជំរះនៅថ្ងៃទី១៦-៧-២០០៤ ចំពោះមុខគូក្ដី និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧-៧-២០០៤ កំបាំងមុខគូក្ដី តែទុកជាចំពោះមុខ ។ បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៣៣២ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤ របស់ឈ្មោះតៅ សុវណ្ណា (ហៅ ជា សុវណ្ណា) ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១០៥"ឈ"ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១១៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៥ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងសាទុក្ខលេខ៣៣២ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤ របស់លោក តៅសុវណ្ណា ហៅ ជា សុវណ្ណា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ១០៥"ឈ"ចុះថ្ងៃទី២៧ខែកក្កដា ឆ្នាំ

២០០៤ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣២៩ចុះថ្ងៃទី២០-៩-២០០៤របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដីដែលចុងចម្លើយ បានបង់ជួសនៅតុលាការកំពូលចំនួន ១៩.០០០៛ គឺ:

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្វ៊ីងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។

៥-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៥ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៥ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៧២"ង"ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងក្ដីរដ្ឋប្បវេណីលេខ ៤០ ចុះថ្ងៃទី១៤-០៧-២០០៥ របស់សាលាឧទ្ធរណ៍តាមអំណាចសាលដីការដ្ឋប្បវេណីលេខ១១៩ ចុះថ្ងៃទី២៣-០៦-២០០៥ របស់តុលាការកំពូលជាថ្មីឡើងវិញ ។

២-ទទួលស្គាល់ផ្ទះ និងដីមួយឡូដ៍ទំហំ៩អារ ៥២សង្ទីអារ ដែលមានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះលី ហេង, ឈ្មោះចាប សល់, ប្លែក ផារី,ខាងត្បូងទល់ផ្លូវជាតិលេខ៦, លឹម គីរិន,យ៉ែម ហៀង, ខាងកើតទល់នឹងដីឈ្មោះលឹម ស៊ិនឡាយ,ឈ្មោះប្លែក ផារី, យុង យុអ៊ី ស្ថិតនៅភូមិបន្ទាយចាស់ ,ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ជាកម្មសិទ្ធិរបស់ឈ្មោះ ជា គឹមលីន ជាចុងចំលើយនៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៣-បង្គាប់ឱ្យដើមចោទឈ្មោះតៅ សុវណ្ណា រុះរើត្ដូបចេញពីដី និងរុះរើតវ៉ាន់ចេញពីលើផ្ទះរបស់ឈ្មោះជា គឹមលីន នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៤-បង្គាប់ឱ្យដើមចោទឈ្មោះតៅ សុវណ្ណា សងជំងឺចិត្តចំនួន ៥០០ដុល្លារអាមេរិក (ប្រាំរយដុល្លារអាមេរិក) ទៅឱ្យចុងចំលើយ នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។ សំណូមពរលើសពីនេះបដិសេធចោល ។

ក្នុងករណីគ្មានប្រាក់សង ត្រូវរឹបអូសទ្រព្យសម្បត្តិរបស់ដើមចោទលក់ឡាយឡុងយកប្រាក់សងចុងចំលើយ ។

៥-កាត់យកប្រាក់ប្រដាប់ក្ដីនៅជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្វ៊ីងចំនួន២៩៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ៥០០០៛ និងលើអាជ្ញាធរតុលាការចំនួន ៥០០០៛ សរុប ១៣.០០០៛ ។

បង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រ១%លើតំលៃដីទំនាស់ និងលើប្រាក់សំណងជំងឺចិត្ត ។

៦-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងចំលើយ មេធាវីចុងចំលើយ កំបាំងមុខដើមចោទ មេធាវីដើមចោទ ។

បានឃើញបណ្តឹងទាស់លេខ ១១៨ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់ឈ្មោះតៅ សុវត្ថា ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៧២"ង"ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសំរេច ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ០៧"ង"ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី០៣-១១-២០០៥ របស់ឈ្មោះតៅ សុវត្ថា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ ៧២"ង"ចុះថ្ងៃទី២៤-១០-២០០៥ របស់សាលាឧទ្ធរណ៍ទុកជាបានការ ។

៣-សាលដីកានេះជំនុំជំរះនៅថ្ងៃទី០៦-០១-២០០៥ ចំពោះមុខគូភាគី មេធាវីការពារក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី១១-០១-២០០៦ ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៩ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់ឈ្មោះតៅ សុវត្ថា ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ០៧"ង"ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣០ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ របស់លោកមេធាវីផាត់ ពៅស៊ាង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ០៧"ង"ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចមិនដាក់គុកបង្ខំរូបរាងកាយ ។

បានឃើញសារណាចុះថ្ងៃទី១៧-០២-២០០៦ របស់លោកតៅ សុវត្ថា ។

បានឃើញសារណាតបចុះថ្ងៃទី២៨-០៣-២០០៦ របស់ឈ្មោះតៅ សុវត្ថា ។

បានឃើញសារណាចុះថ្ងៃទី២០-០២-២០០៦ របស់ឈ្មោះជា គឹមលីន ។

បានឃើញសារណាតប ចុះថ្ងៃទី២០-០៣-២០០៦ របស់ឈ្មោះជា គឹមលីន ។

បានឃើញសាលដីការដ្ឋប្បវេណីរបៀបលេខ ១៨០ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ចាត់របៀបធ្វើការអង្កេតបន្ថែម ហើយបើក្នុងករណីចាំបាច់ចាត់ចៅក្រមប្រឹក្សានៃតុលាការកំពូលចុះពិនិត្យដល់ទីតាំងដីទំនាស់ ។

២-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ ។

បានស្តាប់របាយការណ៍បន្ថែមរបស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : រឿងនេះ គឺជារឿងសុំសិទ្ធិគ្រប់គ្រងដីមរតក ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចំលើយរបស់ឈ្មោះតៅ សុវត្ថា នាពេលសវនការថា : ក្នុងរឿងនេះខ្ញុំពុំមានយោបល់ និងភស្តុតាងអ្វីបន្ថែមទៀតទេ ។

បានស្តាប់ចំលើយរបស់ឈ្មោះជា គឹមលីន នាពេលសវនាការថា : ខ្ញុំសុំបដិសេធនូវសំដីរបស់ឈ្មោះតៅ មន្ថា ដែលថា យាយ ខុងពៃ បានមកសុំពីម្តាយអ្នកស្រីយក តៅ សុវត្ថា តាំងពីតូចពីភ្នំពេញ ទៅចិញ្ចឹម ដោយតៅ សុវត្ថា កំព្រាឪពុក-ម្តាយ ។

ចំណែករឿងថាបានទាក់ទងតាមទូរស័ព្ទជាមួយខ្ញុំអំពីរឿងបែងចែកដីឱ្យឈ្មោះតៅ សុវត្ថា នេះ គឺគ្មានទេ បានសេចក្តីថា ខ្ញុំមិនឯកភាពទាំងអស់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឈុន វៃឌីតា ជាមេធាវីការពារឱ្យដើមចោទបានលើកឡើងថា : ចំពោះរឿងដីដែលជាដីមរតករបស់លោកយាយ ខុង ពៃ ដែលជាយាយបង្កើតរបស់កូនក្តីខ្ញុំឈ្មោះតៅ សុវត្ថា នោះ ខ្ញុំសុំសំណូមពរសុំសិទ្ធិគ្រប់គ្រងចំណែកដីមរតកសពយាយខុង ពៃ ដែលមានក្បាលដីទទឹង ៨.៤ម និង បណ្តោយ៥៥ម ក្នុងមួយចំណែកនៃទំហំដីសរុប ៩៤២ម[២] និងសុំបដិសេធចោលសាលដីការដ្ឋប្បវេណីលេខ ០៣"ង"ចុះថ្ងៃទី១១-០១-២០០៦ របស់សាលាឧទ្ធរណ៍ទុកជាអសារបង់ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយរបស់គូភាគី ,និងសេចក្តីសន្និដ្ឋានរបស់មេធាវីដើមចោទ .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៩ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់លោកតៅ សុវត្ថា និងបណ្តឹងសាទុក្ខលេខ ៣០ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ របស់ផាត់ ពៅសាងមេធាវីការពារឱ្យអ្នកស្រី ជា គឹមលីន ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា ២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលមានអនុភាពអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចទទួលស្គាល់សិទ្ធិរបស់ចុងចំលើយលើដីទំនាស់ទាំងមូលនិងបង្គាប់ឱ្យដើមចោទលោកតៅ សុវត្ថា រុះរើតូបរបស់ខ្លួនចេញពីដី និងរុះរើផ្ទាំង

ចេញពីផ្ទះរបស់ចុងចំលើយដោយសំអាងហេតុថា ដី និងផ្ទះនេះពិតជាត្រូវបានទិញដោយចុងចំលើយពីម្ចាស់ដើមឈ្មោះប៉ុល រឿន តាំងពីឆ្នាំ១៩៨១ មកនោះពុំមានលក្ខណៈត្រឹមត្រូវទេ ពីព្រោះថា ចំលើយរបស់អ្នកស្រីប៉ុល រឿន មានការប្រែប្រួលពុំអាចយកជាការបានទេ ។

- យល់ឃើញថា ចុងចំលើយពុំបានកាន់កាប់ដី និងផ្ទះទំនាស់នេះ ផ្តាច់មុខតែម្នាក់ឯងតាំងពីឆ្នាំ១៩៨១ មកទេ គឺដើមចោទក៏បានកាន់កាប់ និងស្នាក់នៅលើដីនិងផ្ទះនេះដែរ ។

- យល់ឃើញថា ដើមចោទលោកតៅ សុវត្ថា ពិតជាបានមករស់នៅជាមួយចុងចំលើយពីឆ្នាំ១៩៧៩ ឬ ១៩៨១ ប្រាកដមែន ថ្វីបើដើមចោទបានចាកចេញពីផ្ទះនេះនៅឆ្នាំ១៩៨៣ ក៏ពិតមែន ប៉ុន្តែបានត្រឡប់មករស់នៅបន្តពីឆ្នាំ១៩៨៨ រហូតបច្ចុប្បន្នផងដែរ ។

- យល់ឃើញថា ក្នុងការរស់នៅជាមួយចុងចំលើយ ដើមចោទក៏ធ្លាប់បានចាត់ចែងនូវការងារខ្លះៗលើផ្ទះនិងដីទំនាស់នេះដែរ ដោយពុំមានការហាមឃាត់ ឬ រារាំងពីចុងចំលើយទេ ។

- យល់ឃើញថា ថ្វីបើដើមចោទបានស្នាក់នៅនិងចាត់ចែងការងារខ្លះលើដីទំនាស់ក៏ពិតមែន ប៉ុន្តែដើមចោទពុំអាចទទួលសិទ្ធិស្មើនឹងចុងចំលើយដែលជាមេគ្រួសារនោះទេ ដែលគប្បីតុលាការកំពូលពិចារណានិងសំរេចតាមភាពសមហេតុសមផល ។

- យល់ឃើញ សាលដីការដ្ឋប្បវេណីលេខ០៧"ង"ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខថ្មី

១-ទទួលបណ្តឹងសាទុក្ខលេខ១៩ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦របស់លោកតៅ សុវត្ថា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទទួលបណ្តឹងសាទុក្ខលេខ៣០ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦របស់លោកមេធាវី ជាត់ ពៅសាង ការពារឱ្យអ្នកស្រីជា គឹមលីន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

៣-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ០៧"ង"ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៤-បែងចែកដី ABNM ដែលមាន AM=BN=6m និង AB=MN=40,50m តាមគំនូសប្លង់ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦ របស់ចៅក្រមប្រឹក្សាតុលាការកំពូល និងដីចំណីផ្លូវខាងមុខដីនេះឱ្យទៅឈ្មោះតៅ សុវត្ថា កាន់កាប់និងគ្រប់គ្រងតទៅ និងប្រគល់ចំណែកនិងដីចំណីថ្នល់ដែលនៅសល់ និងផ្ទះព្រមទាំងការប្បផ្សេងៗទៀតឱ្យទៅចុងចំលើយអ្នកស្រីជា គឹមលីន កាន់កាប់ និង គ្រប់គ្រងតទៅ ។

៥-បង្គាប់ឱ្យដើមចោទលោកតៅ សុវត្ថា រុះរើតូបរបស់ខ្លួនមកដាក់លើដីចំណែកដែលតុលាការប្រគល់ឱ្យនៅចំណុចទី៤ខាងលើនិងឱ្យឈ្មោះនេះរើឥវ៉ាន់របស់ខ្លួនចុះចេញពីផ្ទះដែលប្រគល់ឱ្យអ្នកស្រីជា គឹមលីន ។

៦-រំលងសប្រាក់ប្រដាប់ក្តីចំនួន៣៨.០០០រៀលដែលអ្នកស្រីជា គឹមលីន បានបង់គឺ :

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្លឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប ១៩.០០០៛ នៅសល់១៩.០០០៛ ប្រគល់ឱ្យអ្នកស្រីជា គីមលីន វិញ ។

បង្គាប់ឱ្យអ្នកស្រីជា គីមលីន បង់ពន្ធសមាមាត្រ១៛លើតម្លៃដី ABNM ដែលត្រូវប្រគល់ឱ្យឈ្មោះតៅ សុវត្ថា និងបង្គាប់ឱ្យតៅ សុវត្ថា បង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃដីទំហំ ៤០.៥០ម x ២.៤០ម ។

៧-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៦។